សលាកប័ត្រព័ត៌មាន NEWSLETTER
លេខ: ៤១ ខែកុម្ភៈ ឆ្នាំ២០០៩
Issue: 41 February 2009

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# អតីតប្រធានមន្ទីរស_២១ ប្រឈមមុខនឹង សវនាការបឋមដោយអង្គជំនុំជម្រះសាលាដំបូង

## Former S-21 Center Chief Facing Initial Hearing by the ECCC's Trial Chamber

អតីតប្រធានមន្ទីរស-២១ (មន្ទីរសន្តិបាល) ឬហៅថាគុក ទួលស្លែង ឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**" ត្រូវបានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកសវនាការបឋម កាលពីថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ កន្លងទៅ ដោយមានការចូលរួមមើលពីសំណាក់អ្នកចូលរួមរាប់រយនាក់ ដែលជាជនរងគ្រោះ ក្រុមគ្រួសារជនត្រូវចោទ សាធារណជនជាតិ និងអន្តរជាតិ។



*វត្តមានរបស់ **ឌុច** នៅក្នុងពេលបើកសវនាការបឋមដោយសាលាដំបូង*

នេះ គឺជាព្រឹត្តិការណ៍លើកដំបូងហើយ ដែលជនត្រូវចោទជាអតីតអ្នកទទួលខុសត្រូវជាន់ខ្ពស់ខ្មែរក្រហម ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបើកសវនាការបឋម នៅមុនគេនៅក្នុងចំណោមជនត្រូវចោទបួនរូបផ្សេងទៀត ដែលបាននឹងកំពុងដាក់ឱ្យស្ថិតក្នុងមន្ទីរឃុំខ្លួន រង់ចាំការកាត់សេចក្តីនៅពេលខាងមុខជាបន្តបន្ទាប់ទៀត។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ គឺជាព្រឹត្តិការណ៍ ដែលប្រជាពលរដ្ឋកម្ពុជាជាច្រើនលាននាក់ បានទន្ទឹងរង់ចាំយ៉ាងអន្ទះសា ក្រោយពេលដែលអំពើឧក្រិដ្ឋកម្មបានកើតឡើងនៅក្នុងរបបខ្មែរក្រហម បានបញ្ចប់ទៅអស់រយៈពេលជិត ៣០ឆ្នាំ មកនេះ។ វាជាពេលវេលាដ៏សំខាន់ ដែលការដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះទាំងឡាយ ដែលបានឈឺចាប់ និងរងនូវទុក្ខវេទនាដោយសាររបបខ្មែរក្រហម ឬរបបវាលពិឃាត ដែលបានបណ្តាលឱ្យមានមនុស្សស្លាប់អស់ជិត ២លាននាក់ តែក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ។

នៅក្រោមក្រសែភ្នែក នៃអ្នកចូលរួមមើលសវនាការទាំងជនជាតិខ្មែរ និងជនបរទេស ជាច្រើនរយនាក់នៅក្នុងសាលសវនាការ អង្គជំនុំជម្រះសាលាដំបូងដែលមានចៅក្រមប្រាំរូប (ចៅក្រមខ្មែរបីរូប និងចៅក្រមអន្តរជាតិពីររូប) ដឹកនាំដោយចៅក្រម **និល ណុន** បានប្រកាសនូវរបៀបវារៈសំរាប់សវនាការបឋមជាលើកដំបូង ទៅលើជនត្រូវចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** នេះ រួមមាន: ១- ការទទួលស្គាល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីថ្មីបន្ថែម ដែលបានដាក់ពាក្យសុំតាំងខ្លួនមកអង្គជំនុំជម្រះសាលាដំបូង, ២- ការទទួលស្គាល់សាក្សី និងអ្នកជំនាញ និងភស្តុតាងសំរាប់បញ្ចូលក្នុងរឿងក្តី និង ៣- ភស្តុតាងថ្មី ដែលជាខ្សែភាពយន្តផលិតឡើង បីថ្ងៃក្រោយរបបខ្មែរក្រហមដួលរលំ ដែលទើបតែដាក់បញ្ជូនដោយការិយាល័យសហព្រះរាជអាជ្ញា។

អតីតប្រធានគុកទួលស្លែង ឈ្មោះ **ឌុច** ត្រូវបានចោទប្រកាន់ពី**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើឃាតកម្ម និងអំពើទារុណកម្ម**នៅក្នុងរយៈពេលគាត់កាន់អំណាចពីចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ នោះ បានបណ្តាលឱ្យមនុស្សប្រមាណ១៦000នាក់ ស្លាប់ដោយការធ្វើទារុណកម្មការសំលាប់ និងអំពើអមនុស្សធម៌ផ្សេងទៀត។ ដូច្នេះហើយ បានជាដើម្បីធានាឱ្យមានយុត្តិធម៌នៅចំពោះមុខចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង **ឌុច** ត្រូវបានការពារក្តីដោយក្រុមសហមេធាវីការពារក្តីចំនួនពីររូបគឺ: លោក **ការ សាវុត្ថ** និងលោក **ហ្វ្រង់ស្វ័រ រូហ្ស**

(ជនជាតិបារាំង)។

នៅក្នុងសវនាការបឋមដែលប្រព្រឹត្តឡើងជាលើកដំបូងនេះ បង្កឱ្យមានការយកចិត្តទុកដាក់ និងផ្តោតអារម្មណ៍ជាខ្លាំងចំពោះការចូលរួមរបស់ជនរងគ្រោះ ដែលបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងប្រឆាំងនឹងជនត្រូវចោទឈ្មោះ **ឌុច** នេះ។ នៅក្នុងសាលសវនាការ និងចំពោះមុខអង្គចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង គេសង្កេតឃើញមានវត្តមានរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន (ទទួលស្គាល់ចំនួន ២៨រូប) និងតំណាងដោយមេធាវីការពារជាច្រើនរូបជា សហមេធាវីជាតិ និងមេធាវីអន្តរជាតិ ដែលមកពីប្រទេសមួយចំនួនដូចជាសហរដ្ឋអាមេរិក អាល្លឺម៉ង់ អង់គ្លេស និងបារាំង។ ការចូលរួមបែបនេះរបស់ជនរងគ្រោះ ដែលជាអ្នកនៅរស់រានមានជីវិតរួចពីការសម្លាប់ និងសាច់ញាតិរបស់ជនរងគ្រោះ ធ្វើឱ្យគេចាប់អារម្មណ៍ថា គឺជាអ្វីមួយដែលពួកគាត់ ដែលជាតំណាងឱ្យជនរងគ្រោះដទៃទៀត ចង់បាននូវ និងស្រេកឃ្លាននូវយុត្តិធម៌ ចំពោះការឈឺចាប់ និងភាពរងគ្រោះរបស់គាត់នៅក្នុងកំឡុងពេលដែលជនត្រូវចោទរូបនេះបានកាន់អំណាចជាប្រធានមន្ទីរសន្តិបាលនាសម័យខ្មែរក្រហមនោះ។

ទិដ្ឋភាពបញ្ហា ដែលត្រូវបានលើកអង្គជំនុំជម្រះសាលាដំបូង យកមកជជែកនៅក្នុងសវនាការបឋមនេះ រួមមានដូចខាងក្រោមនេះ

## ១- ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីថ្មីបន្ថែមទៀត:

- *<u>ជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>*

ការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរការតុលាការ ដែលមានលក្ខណៈអន្តរជាតិ តួយ៉ាងដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាករណីពិសេសមួយ ដែលតំរូវដោយច្បាប់កម្ពុជា និងដោយវិធានផ្ទៃក្នុងរបស់សាលាក្តីពិសេសនេះ។ ការចូលរួមនេះ អនុញ្ញាតឱ្យជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ដើម្បីលើកឡើងនូវអង្គហេតុ និងទាមទារនូវសំណង នៅពេលសំរេចអំពីទោសប្រឆាំងនឹងជនត្រូវចោទនៅពេលខាងមុខ។ មកត្រឹមពេលមុនពេលបើកសវនាការបឋមនេះ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨រូប ដែលត្រូវបានទទួលស្គាល់ ដោយសហចៅក្រមស៊ើបអង្កេត ហើយក៏ត្រូវបានបែងចែកជាបួនក្រុម។

នៅក្នុងសវនាការនោះសហមេធាវីជាតិ និងអន្តរជាតិ សុទ្ធតែ បានលើកឡើងថា មានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល៦៧នាក់ទៀត ដែលចង់ចូលរួមនៅក្នុងសំណុំរឿងនេះ ហើយដែលត្រូវស្នើសុំការទទួលពីសាលាដំបូងនៅពេលនេះ។

- *<u>ករណីលោក **នង ចាន់ផល** អតីតកុមាររស់រានពីការស្លាប់នៅគុកទួលស្លែង:</u>*

ករណីលោក **នង ចាន់ផល** អតីតកុមាររស់រានមានជីវិតនៅគុកទួលស្លែង បន្ទាប់ពីរបបខ្មែរក្រហម ដួលរលំត្រូវបានសហមេធាវីអន្តរជាតិលោក **ការីម ខាន** (មកពីប្រទេសអង់គ្លេស) លើកឡើងក្នុងសវនាការ ដើម្បីស្នើសុំបញ្ចូលធ្វើភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីរបស់ **ឌុច** នេះផងដែរ ដោយសារលោក គឺជាកុមារមួយរូបក្នុងចំណោមកុមារបួនរូប បានរស់រានមានជីវិតពីគុកទួលស្លែង និងដែលមានវត្តមាននៅក្នុងខ្សែភាពយន្តរបស់ផលិតករជនជាតិវៀតណាម ដែលត្រូវស្នើសុំដាក់បញ្ចូលជាភស្តុតាងថ្មីទៅកាន់តុលាការ កាលពីពេលថ្មីៗនេះផងដែរ។ ករណីរបស់ លោក **ចាន់ផល** គឺថា លោកត្រូវបានអង្គភាពជនរងគ្រោះ បដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ដោយសារការមកដាក់ពាក្យយឺតជាងថ្ងៃ កំណត់ទទួលពាក្យចំនួនពីរថ្ងៃ។ ហេតុដូចនេះហើយបានជា មេធាវីស្នើសុំឱ្យតុលាការសាលាដំបូង សំរេចទទួលស្គាល់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត នៅក្នុងសំណុំរឿងនេះដោយមានការគាំទ្រពីសហព្រះរាជអាជ្ញាគាំទ្រផងដែរ។

ជំទាស់នឹងការស្នើសុំសហមេធាវីការពារជនត្រូវចោទ លោក **រូហ្វ** បានលើកឡើងថា ប្រសិនបើអនុញ្ញាតទទួលស្គាល់អ្នកដាក់ពាក្យសុំលើកនេះ នោះតុលាការត្រូវពន្យារពេលផ្សេងលើករណីផ្សេងទៀត ដែលនេះ គឺជាការមិនត្រឹមត្រូវឡើយ។

## ២- ការទទួលស្គាល់សាក្សី អ្នកជំនាញ និងភស្តុតាង:

ទាំងសហព្រះរាជអាជ្ញា លោក **រ៉ូពើត ពើទីត** និងលោកស្រី **ជា លាង** និងក្រុមមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីសុទ្ធបានផ្តល់ឱកាសដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បី

លើកឡើងនូវភស្តុតាង សាក្សី និងអ្នកជំនាញ ទៅក្នុងសំណុំរឿង ដោយត្រូវ ធ្វើឡើងដោយលាក់នូវអត្តសញ្ញាណភាគច្រើន ដូចជា ប្រើអក្សរកាត់ជាភាសាអង់គ្លេស និងលេខកូដសំគាល់ ប្រយោជន៏ ដើម្បីការពារដល់សាក្សីទាំងនេះ។ ដូចគ្នាដែរ ខាងភាគីសហមេធាវី ការពារក៏ត្រូវបានផ្តល់ឱកាសឆ្លើយតបនឹងការដាក់ជូននូវភស្តុតាង បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញទាំងនេះផងដែរ ដើម្បីឱ្យមានការ ឯកភាពគ្នា ទៅលើអ្នកដែលត្រូវទទួលស្គាល់ និងកោះហៅមកចូលរួម នៅពេលបើកសវនាការអង្គសេចក្តីខាងមុខនេះ។

### ៣- ការដាក់បញ្ចូលនូវភស្តុតាងថ្មីជាឯកសារខ្សែភាពយន្តទាក់ទិននឹងទីពិឃាតគុកទួលស្លែង:

បញ្ហាសំខាន់នៅក្នុងដំណាក់កាលបើកសវនាការបឋមនេះដែរ គឺការស្នើសុំដាក់បញ្ចូលជាភស្តុតាងបន្ថែម ដោយសហព្រះរាជអាជ្ញា ដោយសារទើបតែរកឃើញនាពេលថ្មីៗនេះ ដើម្បីសាលាដំបូងទទួលស្គាល់នៅក្នុងសំណុំរឿង។ ភស្តុតាងជាខ្សែភាពយន្តដ៏ចម្រូងចម្រាស់មួយនេះ បានបង្ហាញឱ្យឃើញនូវឈុតឆាកដែលគេរៀបចំផលិតឡើងដោយផលិតករជនជាតិវៀតណាម គឺរយៈពេលបីថ្ងៃបន្ទាប់ពីកងទ័ពវៀតណាមបានចូលមករំដោះប្រជាជនកម្ពុជា ពីរបបខ្មែរក្រហមនៅ ក្នុងបរិវេណគុកទួលស្លែងតែម្តង។ បញ្ហានេះ ត្រូវបានបដិសេធដោយសហមេធាវីការពារ គឺលោក **ការ សាវុត្ថ** ដោយបានអះអាងថា ខ្សែភាពយន្តដែលមិនធ្លាប់បានឃើញនេះ មានចរិតនយោបាយ ហើយមិនឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែងឡើយ។ ហើយជាងនេះទៅទៀត បញ្ហានេះក៏មានជាប់ទាក់ទិននឹងការមិនទទួលស្គាល់កុមារដែលសល់ពីស្លាប់ **នង ចាន់ផល** ដែលបានខកខានក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

គួរបញ្ជាក់ថា នៅក្នុងសវនាការរយៈពេលពីរថ្ងៃនេះ បានបង្កឱ្យមានការចាប់អារម្មណ៏ច្រើនពីសំណាក់អ្នកចូលរួមទាំងអស់។ ប៉ុន្តែទន្ទឹមនឹងនេះក៏បានធ្វើប្រជាពលរដ្ឋជនរងគ្រោះមួយចំនួន ដែលបានចូលរួមស្តាប់នេះមានការយល់ច្រឡំ ឬមិនយល់ច្បាស់ភាគច្រើនអំពីដំណើរការផ្លូវច្បាប់ដ៏ស្មុគស្មាញនេះ ពីព្រោះថា សវនាការបឋមនេះមិនមែនជាសវនាការស្តីពីអង្គសេចក្តី ដែលតំរូវឱ្យចៅក្រមធ្វើការសំរេចជាចុងក្រោយថា ឌុច ត្រូវមានទោស ឬមិនមានទោសនៅឡើយទេ។ វាគ្រាន់តែសវនាការធ្វើឡើង ដើម្បីសំរេចគ្នាជាមុននូវបញ្ហាសំខាន់ៗមួយចំនួនដូចមានបញ្ជាក់នូវក្នុងរបៀបវារៈខាងលើតែប៉ុណ្ណោះ ដើម្បីឱ្យមានការឯកភាពរវាងភាគីទាំងឡាយនៅក្នុងរឿងក្តី តួយ៉ាង ភាគីសហព្រះរាជអាជ្ញា ភាគីជនត្រូវចោទ ហើយ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ជាដើម។

នៅចុងបញ្ចប់នៃសវនាការរយៈពេលពីរថ្ងៃនេះ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង មិនទាន់បានសំរេចអំពីលទ្ធផលអ្វីនៅឡើយទេ ហើយថានឹងប្រកាសលទ្ធនាពេលក្រោយបន្ទាប់ទៀត។ ចំពោះកាលបរិច្ឆេទពិតប្រាកដ នៃការបើកសវនាការទាក់ទិននឹងអង្គសេចក្តីទៅលើសំណុំរឿងរបស់ **ឌុច** ត្រូវបានអង្គជំនុំជម្រះសាលាដំបូងប្រកាសឱ្យដឹងជាសាធារណៈថា នឹងធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ខាងមុខនេះ។

## អង្គបុរេជំនុំជម្រះបើកសវនាការបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំ របស់ជនត្រូវចោទជាលើកទី២

## Second Pre-Trial Chamber Hearings on Pre-Trial Detention Appeals Lodged by the Accused

នៅខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមការបើកសវនាការបឋមទៅលើសំណុំរឿងអតីតប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** កាលពីអំឡុងពាក់កណ្តាលខែកុម្ភៈកន្លងទៅនេះ សំណុំរឿងបណ្តឹងឧទ្ធរណ៏សុំនៅក្រៅឃុំរបស់ជនត្រូវចោទដែលជាអតីតមេដឹកនាំជាន់ខ្ពស់ចំនួនបីរូបទៀត ក៏ត្រូវបានអង្គបុរេជំនុំជម្រះលើកយកមកបើកសវនាការបណ្តឹងឧទ្ធរណ៏ជាលើកទី២ទៀត នៅក្នុងអំឡុងចុងខែកុម្ភនេះ ជាបន្តបន្ទាប់ផងដែរ។

ជាក់ស្តែងអង្គបុរេជំនុំជម្រះ បានបើកសវនាការទៅបណ្តឹងឧទ្ធរណ៏សុំនៅក្រៅឃុំបណ្តោះអាសន្នជាលើកទី២ ទៅលើជនត្រូវចោទ **អៀង ធីរិទ្ធិ** ដែលជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩។ លោកចៅក្រម **ប្រាក់ គីមសាន្ត** ដែលជាប្រធានអង្គបុរេជំនុំជម្រះបានអានសារំតា និងបទចោទប្រកាន់មកលើជនត្រូវចោទ ព្រមទាំងអំណះអំណាងផ្នែកច្បាប់ដែលសហមេធាវី ការពារក្តីឱ្យជនត្រូវចោទស្នើសុំនៅក្រៅឃុំបណ្តោះ និងអំណះអំណាងឆ្លើយតបរបស់ភាគីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។

នៅខណៈពេលដែលមានវត្តមាន នៅចំពោះមុខសវនាការ

បណ្តឹងឧទ្ធរណ៍ នៃអង្គបុរេជំនុំជម្រះ នៅខណៈនេះ ជនត្រូវចោទ **អៀង ធីរិទ្ធ** ដែលត្រូវបានការពារដោយសហមេធាវី **លោក ផាត់ ពៅសៀង និងកញ្ញា ដាយអាណា អេលីស** បានមានមតិខ្លាំងៗជំទាស់នឹងការនាំខ្លួនលោកស្រីមកកាត់សេចក្តីនេះ ពីព្រោះថា លោក ស្រីបានបដិសេធថាមិនជាប់ពាក់ព័ន្ធនឹងការកាប់សំលាប់ ដូចការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត អំពីអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ហើយផ្ទុយទៅវិញលោកស្រីបែរជាទំលាក់កំហុសនិងការទទួលខុសត្រូវនេះទៅលើអតីតមេដឹកនាំពីររូបទៀត គឺ **នួន ជា** និង **ឌុច**។

ការបើកសវនាការបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំនេះ គឺធ្វើឡើងជាលើកទី២ ហើយចំពោះជនត្រូវចោទ អៀង ធីរិទ្ធ ក្រោយពីសហចៅក្រមស៊ើបអង្កេត សំរេចដាក់ឃុំខ្លួនបណ្តោះអាសន្ន១ឆ្នាំទៀត បន្ទាប់ពីការសំរេចសាលដីកាលើកទី១ កាលពីឆ្នាំ២០០៨ កន្លងទៅ។

ដោយឡែកនៅទន្ទឹមនឹងពេលនេះដែរលោក **អៀង សារី** ដែលធ្លាប់ធ្វើជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងការបរទេស និងត្រូវជាស្វាមីរបស់លោកស្រី **អៀង ធីរិទ្ធ** ក៏ត្រូវបានអង្គជំនុំជម្រះសំរេចបើកសវនាការបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំបណ្តោះអាសន្ន ជាលើកទី២ របស់លោកផងដែរ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩។ ប៉ុន្តែសវនាការបណ្តឹងឧទ្ធរណ៍លើកនេះ មិនអាចដំណើរការឱ្យបានចប់ចុងចប់ដើមឡើយដោយមូលហេតុថា ជនត្រូវចោទដែលមានអាយុ៨៤ឆ្នាំ មានសុខភាពមិនល្អ ហើយដែលត្រូវនាំទៅកាន់មន្ទីរពេទ្យកាល់ម៉ែត្រ ព្យាបាលជាបន្ទាន់ដោយសារសភាពជំងឺដ៏រ៉ាំរ៉ៃរបស់គាត់។ ដូចនេះលោកចៅក្រមប្រធានអង្គបុរេជំនុំជម្រះបានសំរេចផ្អាកជាបណ្តោះអាសន្ន និងត្រូវលើកពេលបន្តទៀតនៅអំឡុងខែមេសា ខាងមុខទៀត។

ចំពោះអតីតប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ លោក **ខៀវ សំផន** វិញ ក៏មិនខុសពីអតីតមេដឹកនាំផ្សេងទៀតដែរ គឺថា បច្ចុប្បន្នជនត្រូវចោទរូបនេះ ត្រូវបានដាក់ឱ្យស្ថិតក្នុងមន្ទីរឃុំខ្លួនបណ្តោះអាសន្ន ក្រោមបទចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត ចំនួនពីរគឺៈ **អំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** និង **ឧក្រិដ្ឋកម្មសង្គ្រាម**។ បញ្ហាចោទនៅក្នុងសំណុំរឿងរបស់លោកបន្ទាប់ពីត្រូវបានចាប់ខ្លួន និងឃុំខ្លួន កាលពីខែវិច្ឆិកា ឆ្នាំ២០០៧ កន្លងទៅ គឺត្រូវបានសហមេធាវីការពារក្តីរបស់លោក គឺលោកមេធាវី **សរ សុវ៉ាន និងលោក ហ្សាក វែហ្សែស** (ជនជាតិបារាំង) ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នជាបន្តបន្ទាប់ (លើកទី១ និងលើកទី២) ទាក់ទិននឹង **បញ្ហាបកប្រែភាសាឯកសារសំណុំរឿង**។ លោក **ហ្សាក វែហ្សែស** ធ្លាប់បានអះអាងថា តុលាការមិនអាចឃុំខ្លួនកូនក្តីរបស់គាត់ឡើយ នៅខណៈពេលសំណុំឯកសារ ដែលយកមកប្រើប្រាស់ ដើម្បីចោទប្រកាន់ដ៏ច្រើន មិនទាន់ត្រូវបានបកប្រែឱ្យបានរួចរាល់ពីភាសាខ្មែរទៅជាភាសាបារាំង ដែលជាភាសាមួយ ប្រើប្រាស់ជាផ្លូវការនៅក្នុងតុលាការ។ តាមអំណះអំណាងរបស់សហមេធាវីការពារក្តី គឺការមិនមានឯកសារជាភាសាបារាំងទាំងស្រុងនេះ អាចនាំឱ្យប៉ះពាល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានជំនុំជម្រះ ដោយយុត្តិធម៌ និងពេញលេញ ដោយសារថា មេធាវីការពារក្តីមិនអាចយល់បាននូវឯកសារ និងភស្តុតាងដាក់បន្ទុកមកលើកូនក្តីរបស់ខ្លួនឱ្យបានពេញលេញ សវនាការបណ្តឹងឧទ្ធរណ៍លើកទី២ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រូវបានលើកពេលទៅវិញ ដោយសារអវត្តមានលោក **ហ្សាក វែហ្សែស**។

ទោះបីនៅជាសវនាការបណ្តឹង ឧទ្ធរណ៍ជាបន្តបន្ទាប់គ្នានេះ បានប្រព្រឹត្តទៅចប់សព្វគ្រប់យ៉ាងក៏ដោយ ចៅក្រមនៃអង្គបុរេជំនុំជម្រះ នៅមិនទាន់អាចសំរេចលទ្ធផល ថាតើត្រូវដោះលែងជនត្រូវចោទទាំងបីនេះ ឱ្យនៅក្រៅឃុំបណ្តោះ ឬយ៉ាងណានោះនៅឡើយទេ បើទោះបីជាជនត្រូវចោទទាំងនេះ បានត្រូវឃុំខ្លួនបានជាងមួយឆ្នាំហើយ គិតរហូតមកទល់ពេលនេះក៏ដោយ។

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី(NED) និង ឌី.អ៊ី.ឌី(DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយៈ អ៊ិន.អ៊ី.ឌី និង ឌី.អ៊ី.ឌី**

## ព័ត៌មានសំខាន់ៈ

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ចូលរួមដាក់ពាក្យបណ្តឹង**ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្តីខ្មែរក្រហម**

**សូមទាក់ទងៈ**

- **សមាគមសិទ្ធិមនុស្សអាដហុក (ADHOC)**
  លេខទូរស័ព្ទៈ ០២៣ ៩៩០ ៥៤៤
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID)
  លេខទូរស័ព្ទៈ ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)
  លេខទូរស័ព្ទៈ ០២៣ ៣៦៤ ៧៣៥
- អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRO)
  លេខទូរស័ព្ទៈ ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទៈ ០២៣ ២១៤ ២៩១

➢ ស្តាប់កម្មវិធីឃ្លាំមើលសាលាក្តីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញតាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ www.krtrial.info